មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

<u>វិចារណកថាព័ត៌មាន – ភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២</u>

# ម.ស.ម.ក ជម្រុញឲ្យមន្ត្រីតុលាការពន្លឿននីតិវិធីឧទ្ធរណ៍នៅក្នុងករណីស្ត្រីស្រឡាញ់ភេទដូចគ្នាដ៏ចម្រូងចម្រាស់

កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ កាសែត ឌឺ ភ្នំពេញប៉ុស្តិ៍ ("អ.បជួយចេញថ្លៃមេធាវីនៅនីតិវិធីឧទ្ធរណ៍នៃសំណុំរឿងស្ត្រីស្រឡាញ់ភេទដូចគ្នា") បានរាយការណ៍ថា ការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធមនុស្ស កំពុងចេញសោហ៊ុយមេធាវីសម្រាប់នីតិវិធីឧទ្ធរណ៍នៃករណីស្ត្រីស្រឡាញ់ភេទដូចគ្នា។ ផ្លុង ស្រីវ៉ាន់ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ ពីថ្ងៃក្រោយដែលបងប្រុសរបស់[មិត្តស្រីនាង] បានដាក់បណ្តឹងប្រឆាំងនឹងរូបនាងពីបទឃុំឃាំងមនុស្សខុសច្បាប់ និងជួញដូរមនុស្ស។ ក្នុងខែកញ្ញា ឆ្នាំ២០១១ ចៅក្រមសាលាដំបូងបានរកឃើញថានាងមានពិរុទ្ធភាពពីបទរួមភេទជាមួយអនីតិជន ហើយសម្រេចផ្តន្ទាទោសនាងឲ្យជាប់ពន្ធនាគាររយៈពេល៥ឆ្នាំ។ ក៏ប៉ុន្តែមានវិមតិសង្ស័យជាច្រើននៅលាយឡំក្នុងសាលក្រមតុលាការដោយអង្គហេតុមួយចំនួននៃសំណុំរឿងនេះ។ រហូតមកដល់ពេលនេះ នាងត្រូវបានគេឃុំខ្លួនអស់រយៈពេលជាង៦ខែហើយ បើរាប់បញ្ចូលទាំងការឃុំខ្លួនបណ្តោះអាសន្នមុនការជំនុំជម្រះ ប៉ុន្តែនាងទើបតែមានជំនួយផ្នែកច្បាប់ ដែលនាងអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាដំបូងបាន។

កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានចេញផ្សាយ (<u>"សៀវភៅមគ្គុទេសន៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ")</u> ដែលក្នុងនោះមានបកស្រាយអំពីសារៈសំខាន់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យាពេល ដោយធានាថា ជនជាប់ចោទដែលត្រូវបានឃុំខ្លួនក្នុងកំឡុងពេលសវនាការមិនត្រូវបានដកហូតសសេរីភាពយូរហួសពីភាពចាំបាច់ទេ។ សិទ្ធិនេះក៏មានគោលបំណងកាត់បន្ថយនូវភាពអយុត្តិធម៌ ដោយធានាថាបុគ្គលគ្មានកំហុស ដែលរងការចោទប្រកាន់ពីបទល្មើស នឹងមិនត្រូវបានបន្តឃុំខ្លួនក្នុងរយៈពេលមួយយូរហួស ដោយសារបទល្មើសដែលខ្លួនមិនបានប្រព្រឹត្តឡើយ។

កាលពីថ្ងៃទី២៦ ខែមករា កន្លងទៅ កាសែត ឌឺ ភ្នំពេញប៉ុស្តិ៍បានដកស្រង់សំដីរបស់ ផ្លុង ស្រីវ៉ាន់ ថា នាងមានក្តីព្រួយបារម្ភក្រៃលែងចំពោះគ្រួសាររបស់នាង ដែលធ្លាប់តែពឹងពាក់ទាំងស្រុងលើចំណូលរបស់នាងប្រចាំខែតែ៦១ដុល្លា។ នាងបន្ថែមថា *"ខ្ញុំគឺជាបង្គោល និងជាប្រភពចំណូលនៃគ្រួសារ.....គ្រួសារខ្ញុំក្រីក្រណាស់"* ។ កាលពីម្សិលមិញកាសែតដដែលបានរាយការណ៍ថាគ្រួសាររបស់ស្រីវ៉ាន់ ទើបតែបានបាត់បង់ផ្ទះជួលរបស់ពួកគេនៅខេត្តកណ្តាល ដោយសារតែពួកគេពុំមានលទ្ធភាពបង់ប្រាក់ជួលពីព្រោះកន្លងមកគឺពួកគេយកចំណូលដែលស្រីវ៉ាន់រកបានដើម្បីបង់។ ប្រសិនបើនាងមិនមានទោសទេនោះ ជាប្រការមួយដ៏ចាំបាច់ដែលនាងគួរត្រូវបានគេដោះលែងឲ្យមានសេរីភាពឡើងវិញដោយគ្មានពន្យាពេល។

**ឆ្លើយតបទៅនឹងព័ត៌មាននេះ លោក ហែម សុខលី មន្ត្រីសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញានយេនឌ័រ របស់ ម.ស.ម.ក ដែលធ្វើការដើម្បីការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ តាមរយៈការចងក្រង និងគាំទ្រ បណ្តាញអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ នៅកម្ពុជា និងពង្រឹងអំណាចពួកគេឲ្យធ្វើការតស៊ូមតិដើម្បីសិទ្ធិសេរីភាពរបស់ពួកគេ អត្ថាធិប្បាយថា៖**

*"យើងស្វាគមន៍ចំពោះការសម្រេចចិត្តរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលបានឧបត្ថម្ភជំនួយផ្នែកច្បាប់ដល់ស្រីវ៉ាន់។ យើងក៏សូមឆ្លៀតយកឱកាសនេះដើម្បីស្នើដល់ប្រធានសាលាឧទ្ធរណ៍ឲ្យពន្លឿននីតិវិធីនៃករណីនេះ។ តុលាការគួរដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់សមភាព និងសេរីភាពនៃបុគ្គលគ្រប់រូប ដោយធានាយុត្តិធម៌ និងធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សកល ជាពិសេសតុលាការត្រូវធានាថាមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងរយៈពេលមួយសមស្រប។ ការស៊ើបអង្កេតពេញលេញ និងដោយសុក្រិត្យមួយគួរត្រូវបានធ្វើឡើងដោយមន្ត្រីតុលាការមានសមត្ថភាព ឯករាជ្យ និងអព្យាក្រិត្យ។ សិទ្ធិទាំងនេះមានតម្លៃជាធម្មនុញ្ញភាព ដូចដែលបានចែងក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាថា ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។"*

សម្រាប់ព័ត៌មានបន្ថែមទំនាក់ទំនងលោក ហែម សុខលី តាមរយៈទូរស័ព្ទលេខ ០៩២ ៨០៥ ៨០៨ ឬតាមរយៈអ៊ីមែល **<u>soklyhem@cchrcambodia.org</u>**